ការិយាល័យសេវាផ្លូវថ្នល់ (Bureau of Street Services, BSS ដោយមានការគាំទ្រពីបទប្បញ្ញត្តិច្បាប់ទីក្រុង Los Angeles (ទីក្រុង ស្តីពី ការលក់ដូរតាមចិញ្ចើមផ្លូវសម្រាប់សំណុំរឿងក្រុមប្រឹក្សាលេខ
13-1493-S5 បានរៀបចំវិធាននិងបទប្បញ្ញត្តិទូទៅដូចខាងក្រោមសម្រាប់អាជីវករលក់ដូរតាមចិញ្ចើមផ្លូវ នៅក្នុងការផ្តល់សិទ្ធិអាទិភាពសាធារណៈ។ រាល់ការលក់ដូរតាមចិញ្ចើមផ្លូវទាំងអស់ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2019 តទៅ នឹងត្រូវស្ថិតក្រោមការគ្រប់គ្រងដោយវិធានទាំងនេះ។

1. *សំរាម៖* គ្រប់រទេះ ឬតូបលក់ដូរចំណីអាហារទាំងអស់ ត្រូវមានបំពាក់ដោយធុងសំរាមធំល្មមដើម្បីដាក់សំរាមទាំងអស់ដែលកើតមានតាមរយៈដំណើរការនៃរទេះ ឬតូបទាំងនោះ ហើយប្រតិបត្តិកររទេះទុញ ឬតូបលក់ចំណីអាហារនោះ ត្រូវរើសសំរាមដែលកើតចេញពីប្រតិបត្តិការលក់ដូរនោះនៅក្នុងរយៈចម្ងាយ 50 ហ្វូត ពីរទេះរុញ ឬតូបទាំងនោះនៅមុនពេលផ្លាស់ប្តូរទីតាំងរទេះនោះ។ គ្រប់របស់ដែលអាចកែច្នៃប្រើប្រាស់ឡើងវិញបានទាំងអស់ ត្រូវញែកចេញពីសំរាម ហើយត្រូវបោះចោលឲ្យបានត្រឹមត្រូវស្របទៅតាមគោលនយោបាយកែច្នៃប្រើប្រាស់ឡើងវិញរបស់ទីក្រុង Los Angeles (ទីក្រុង បច្ចុប្បន្ន។

2. *បំពង់បឺតជ័រប្រើរួចបោះចោល៖ អាជីវករ និងប្រតិបត្តិករផ្សារកសិករ ត្រូវអនុវត្តតាមមាត្រា 3 ជំពូក XIX នៃ LAMC។*

3. *ការដាក់លក់៖* ពុំមានបុគ្គលណាម្នាក់ អាចដំឡើង ប្រើប្រាស់ ឬរក្សាទុករទេះឬតូបលក់ដូរ ដែលលយទៅលើ ទៅក្នុង ឬនៅលើផ្លូវថ្មើរជើង ឬកន្លែងចំណតណាមួយនោះទេ នៅពេលណាការដំឡើង ការប្រើប្រាស់ ឬការថែទាំនោះ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃបុគ្គល ឬទ្រព្យសម្បត្តិ ឬនៅពេលដែលកន្លែងឬទីតាំងនោះ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសេវាសាធារណៈ គោលបំណងការដឹកជញ្ជូនសាធារណៈ ឬការប្រើប្រាស់ផ្សេងទៀតរបស់រដ្ឋាភិបាល ឬនៅពេលដែលរទេះឬតូបនោះមានការប៉ះពាល់មិនសមស្រប ឬរារាំងដល់លំហូរធ្វើដំណើរនៃអ្នកថ្មើរជើងឬចរាចរណ៍យានជំនិះ ការចូលទៅក្នុងច្រកផ្លូវ ឬការចេញពីច្រកផ្លូវលំនៅដ្ឋាន ឬកន្លែងអាជីវកម្មណាមួយ ឬការប្រើប្រាស់បង្គោល សសរ ផ្លូវចរាចរណ៍ គំនូសសញ្ញាឬស្លាកសញ្ញាចរាចរណ៍ ក្បាលបំពង់ទឹកទីក្រុង ប្រអប់សំបុត្រ ឬវត្ថុផ្សេងទៀតដែលត្រូវបានអនុញ្ញាតឲ្យស្ថិតនៅក្បែរទីតាំងដែលបានលើកឡើងនេះ។ គ្មានរទេះ ឬតូបលក់ដូរណាមួយ ត្រូវដាក់នៅកន្លែងដែលបានរៀបរាប់មកនោះទេ ដែលធ្វើឲ្យចន្លោះទំនេរប្រើសម្រាប់ជាផ្លូវរបស់អ្នកថ្មើរ

ដើងនៅលើចិញ្ចើមផ្លូវ រួមតូចដោយមានទទឹងតិចជាងប្រាំហ្វីតឡើយ។ គ្មានអាជីវករចល័ត ឬអាជីវករតាមដងផ្លូវណាម្នាក់ អាចបិទផ្លូវ ឬបង្កឲ្យមានការបិទច្រកចិញ្ចើមផ្លូវ ផ្លូវថ្នល់ វុត្តវិថី ផ្លូវឡើងហែម ឬទីតាំងសាធារណៈណាមួយ ដែលបណ្តាលឲ្យមនុស្សប្រមូលផ្តុំគ្នានៅត្រង់ ឬនៅក្បែរកន្លែងកំពុងដាក់លក់ ឬបើកលក់ដូរនៃទំនិញ របស់របរ ចំណីអាហារ ឬសម្ភារៈលក់ដូរគ្រប់ប្រភេទបានឡើយ។

a) ចម្ងាយពីគ្រឿងបរិក្ខារខ្ពស់ផុតពីដី (above ground facilities, AGF) ខាងក្រោមនេះ មិនត្រូវតិចជាងបីហ្វីតនោះទេ៖
   (1) អំពូលភ្លើងបំភ្លឺផ្លូវ
   (2) ជាយនៃប្រហោងរណ្តៅទឹកកកក្បែរដើមឈើ
   (3) កុងទ័រចំណត
   (4) រចនាសម្ព័ន្ធគ្រឿងបរិក្ខារខ្ពស់ផុតពីដី
b) ចម្ងាយពីក្បាលបំពង់ទឹកពន្លត់អគ្គិភ័យ ត្រូវមានចម្ងាយមិនតិចជាងប្រាំហ្វីតនោះទេ។
c) ចម្ងាយពីប្រអប់គ្រឿងបរិក្ខារខាងក្រៅដែលមានស្រាប់ វ៉ានទឹក ឬក្បាលវ៉ាន ត្រូវមានចម្ងាយមិនតិចជាងពីរហ្វីតនោះទេ។
d) ចម្ងាយពីគែមផ្លូវ និងពីជាយផ្លូវបើកបរដែលមានស្រាប់ មិនត្រូវតិចជាង 18 អ៊ិញនោះទេ (សូមមើល ដ្យាក្រាម 1។
e) ចម្ងាយពីអាជីវករមួយទៅអាជីវករមួយ ត្រូវមានគម្លាតប្រវែងបីហ្វីត (សូមមើល ដ្យាក្រាម 2។
f) ពុំអនុញ្ញាតឲ្យមានទីធ្លាលក់ដូរណាមួយ បើកដំណើរការនៅទីតាំងចំណតរថយន្តក្រុង ឬនៅទីតាំងដែលមានគ្រឿងបរិក្ខារខ្ពស់ផុតពីដីដែលមានស្រាប់ ដូចជា គ្រឿងសង្ហារឹមតាមដងផ្លូវ (បង់អង្គុយ របារសម្រាប់ដាក់កង់ តូបលក់កាសែត ឬគែមផ្លូវដែលបាញ់គំនូសក្រហម (សូមមើល ដ្យាក្រាម 3 ។
g) ពុំអនុញ្ញាតឲ្យមានកន្លែងលក់ដូរណាមួយ ដំណើរការលើផ្លូវចរាចរណ៍ អ័ក្សទ្រូងផ្លូវ សួនច្បារកណ្តាលទ្រូងផ្លូវ និង ផ្លូវសម្រាប់ជិះកង់នោះទេ។

h) ពុំមានទីតាំងទូរដាក់លក់ទំនិញណាមួយ ត្រូវដាក់នៅចំពីមុខអគារដោយផ្ទាល់នោះទេ។ រាល់ទីតាំងទូរលក់ទំនិញទាំងអស់ ត្រូវដាក់នៅចម្ងាយ 18 អ៊ិញ ពីលើគែមចិញ្ចើមផ្លូវ។

i) ចម្ងាយពីសកម្មភាពដែលបានអនុញ្ញាត រួមមានជាអាទិ៍ការហ៊ុំព័ទ្ធផ្លូវ ឬគន្លងផ្លូវដែលពាក់ព័ន្ធនឹងការដ្ឋានសំណង់ ឬព្រឹត្តិការណ៍ពិសេសៗ ការប្រមូលផ្តុំមហាជន ការថតភាពយន្ត និងទីផ្សារកសិករ ត្រូវមានចម្ងាយមិនឲ្យតិចជាង 500 ហ្វីតពីខ្សែបន្ទាត់ព្រំដែននៃសកម្មភាពដែលបានអនុញ្ញាតនោះទេ។

j) ចម្ងាយពីច្រកផ្លូវចូលទៅកាន់អគារ ហាងទំនិញ រោងមហោស្រព រោងភាពយន្ត រោងជាង ឬកន្លែងជួបជុំជាសាធារណៈណាមួយ ត្រូវមានចម្ងាយអប្បបរមា 20 ហ្វីត។

k) ចម្ងាយពីទីតាំងលក់ដូរដែលមានលក្ខខណ្ឌកម្រិត ដូចមានចែងដោយក្រមរបស់ទីក្រុង Los Angeles ផ្នែក 42.13(c ត្រូវមានចម្ងាយមិនឲ្យតិចជាង 500 ហ្វីត ពីព្រំអចលនទ្រព្យនៃទីតាំងដែលបានដាក់កំហិតនោះទេ។

4. *ទីតាំងលក់ដូរដែលមានការហាមឃាត់៖*

a) ការលក់ដូរត្រូវបានហាមឃាត់ក្នុងចម្ងាយ 500 ហ្វីតពី៖

(1) The Hollywood Walk of Fame, Universal Studios និង នេះ El Pueblo de Los Angeles Historical Monument, Staples Center/LA Live (ដូចមានចែងនៅក្នុងជំពូក 25 នៃភាគទី 22 នៃក្រមទីក្រុង Los Angeles;

(2) Dodger Stadium, នេះ Hollywood Bowl, និង នេះ LA Coliseum/Banc of California Stadium នៅថ្ងៃដែលមានរៀបចំព្រឹត្តិការណ៍;

***(3) ព្រលានយន្តហោះអន្តរជាតិ Los Angeles និង***

(4) និងទីតាំងផ្សេងទៀត ដូចបានកំណត់ដោយគណៈកម្មការសាធារណការ។

b) ការលក់ដូរនៅ Venice Beach ត្រូវបានកំណត់សម្រាប់តែសកម្មភាពបញ្ចេញមតិដែលទទួលបានការការពារដោយវិសោធនកម្មលើកទីមួយប៉ុណ្ណោះ។

c) សាលារៀន ឬគ្រឹះស្ថានអប់រំក្រោយមធ្យមសិក្សាដែលចូលរួមដោយសិស្សមធ្យមសិក្សា ឬគ្រឹះស្ថានមត្តេយសិក្សាឯកជន សាលាបឋមសិក្សា ឬមធ្យមសិក្សា។

ផែនទីសម្រាប់ទីតាំងនីមួយៗ នឹងបង្ហាញពីព្រំដែន។ ស្លាកសញ្ញាសមស្រប ដែលហាមមិនឲ្យមានកន្លែងលក់ដូរ នឹងត្រូវដាក់បង្ហាញនៅតាមទីតាំងទាំងអស់នេះ។

5. *ការលក់ដូរផលិតផល៖* រាល់ផលិតផលទាំងអស់ ដែលកំណត់ដោយនាយកដ្ឋានចំណីអាហារ និងកសិកម្មរដ្ឋកាលីហ្វ័រញ៉ា (California Department of Food and Agriculture, CDFA) ត្រូវគ្រប់គ្រង ដឹកជញ្ជូន តាំងបង្ហាញ ឬបោះចោលស្របទៅតាមបទប្បញ្ញត្តិទាំងអស់របស់ CDFA ដោយសារបច្ចុប្បន្ននេះ បទប្បញ្ញត្តិនេះមាន ឬត្រូវបានកែប្រែពីពេលមួយទៅពេលមួយ ដែលមានជាអាទិ៍ដូចខាងក្រោម៖

a) រាល់ផលិតផល ឬទំនិញទាំងអស់ត្រូវស្ថិតក្រោមផ្នែកចត្តាឡីស័កនៃ CDFA នឹងត្រូវបានការពារ ឬឃ្លាំមើលក្នុងលក្ខណៈដែលបានយល់ព្រម ដោយមានការវេចខ្ចប់ ឬការត្រួតពិនិត្យដើម្បីការពារការឆ្លងរោគ។ រាល់ការតាំងបង្ហាញដោយបើកចំហរណាមួយ ត្រូវបានហាមឃាត់។
b) គ្រប់ផលិតផល ទំនិញ ឬសំបក ស្នូល ឬគ្រាប់ ត្រូវបិទភ្ជិតនៅក្នុងថង់ផ្លាស្ទិកនៅមុនពេលបោះចោល។
c) អាជីវករលក់ចំណីអាហារណាមួយ ត្រូវមានបង្កាន់ដៃបង់ប្រាក់ វិក្កយបត្រ ប័ណ្ណដឹកជញ្ជូន ឬភស្តុតាងបញ្ជាក់ប្រភពដើមផ្សេងទៀតដែលអាចទទួលយកបាននៃផលិតផល ឬទំនិញស្ថិតក្រោមផ្នែកចត្តាឡីស័ក។
d) រាល់ផលិតផល ឬទំនិញទាំងអស់ស្ថិតក្រោមផ្នែកចត្តាឡីស័ក ដែលត្រូវបានលក់ ផ្តល់ជូនសម្រាប់លក់ ឬដឹកជញ្ជូននៅក្នុងតំបន់ចត្តាឡីស័ក ត្រូវមានបញ្ជាក់ពីប្រភពដើមផ្នែកពាណិជ្ជកម្ម។
e) ការបំពានណាមួយលើផ្នែកនេះ អាចឈានដល់ការឃាត់ទុកផលិតផល ឬទំនិញនោះ។

6. *លិខិតអនុញ្ញាត៖* រាល់អាជីវករនៅតាមចិញ្ចើមផ្លូវទាំងអស់ ត្រូវមានលិខិតអនុញ្ញាតអាជីវកម្ម ពន្ធ និងលិខិតអនុញ្ញាតផ្នែកសុខាភិបាលដែលមានសុពលភាព ដែលតម្រូវដោយរដ្ឋ ខោនធី និង/ឬទីក្រុង។

**Diagram 1**




**Diagram 2**




**Diagram 3**
(not to scale)

